**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តកំពង់ស្ពឺ**
លេខៈ ៦២ ដីក

# ដីកា

## ស្តីពីការបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈ

## អភិបាល នៃគណៈអភិបាលខេត្តកំពង់ស្ពឺ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ ០៦ នស/៩៤ ចុះថ្ងៃទី ៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១៦/៣១៦ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦ របស់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តមសីហមុនី ព្រះមហាក្សត្រនៃព្រះរាជណាចក្រកម្ពុជា ត្រាស់បង្គាប់តែងតាំងអភិបាល នៃគណៈអភិបាលខេត្តកំពង់ស្ពឺ
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទីភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ ២៨៦ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ស្តីពីនីតិវិធីសម្រាប់ការរៀបចំការកែប្រែ និងការលុបចោលដីការបស់ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញប្រកាសលេខ ៤២៧៤ ប្រក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៩ របស់ក្រសួងមហាផ្ទៃ ស្តីពីការបង្កើតការិយាល័យចំណុះ ទីចាត់ការនៃសាលាខេត្ត ការបង្កើតការិយាល័យនៃសាលាក្រុង ការបង្កើតការិយាល័យនៃសាលាស្រុក និងការកំណត់តួនាទីភារកិច្ច របៀបរបបការងារ នៃការិយាល័យទាំងនោះ
- យោងលិខិតលេខ ១៨៤៦ មស.គករ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៦ របស់ក្រសួងមុខងារសាធារណៈ
- យោងលិខិតលេខ ១៥២០ ស.ជ.ណ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៦ របស់ក្រសួងមហាផ្ទៃ
- យោងតាមស្មារតីនៃកិច្ចប្រជុំសាមញ្ញារបស់ក្រុមប្រឹក្សា នាថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៦

**ប្រការ១.-**

ត្រូវបានបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈនៅរដ្ឋបាលខេត្តកំពង់ស្ពឺ ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១-ឯកឧត្តម **ខុ សំណាង** | អភិបាលខេត្ត | ប្រធាន |
| ២-លោក **សរ សុពុត្រា** | អភិបាលរងខេត្ត | អនុប្រធាន |
| ៣-លោក **កង វណ្ណារ៉ូ** | នាយករដ្ឋបាលសាលាខេត្ត | អនុប្រធាន |
| ៤-លោកស្រី **ឈុំប សុធាន** | ប្រធានមន្ទីរមុខងារសាធារណៈខេត្ត | អនុប្រធានអចិន្ត្រៃយ៍ |
| ៥-លោក **ទេស សុខុន** | នាយកទីចាត់ការគ្រប់គ្រងធនធានមនុស្សសាលាខេត្ត | សមាជិក |
| ៦-លោក **ចាន់ សុគន្ធ** | នាយកទីចាត់ការរដ្ឋបាលសាលាខេត្ត | សមាជិក |
| ៧-លោក **ស្មួស ថុល** | នាយកទីចាត់ការហិរញ្ញវត្ថុសាលាខេត្ត | សមាជិក |
| ៨-លោក **ចិន សារ៉េត** | នាយកទីចាត់ការផែនការ និងវិនិយោគសាលាខេត្ត | សមាជិក |
| ៩-លោក **វ៉ាន់ សុខា** | នាយកទីចាត់ការអន្តរវិស័យសាលាខេត្ត | សមាជិក |
| ១០-លោក **ម៉ែន ចន្ធី** | ប្រធានអង្គភាពលទ្ធកម្មសាលាខេត្ត | សមាជិក |
| ១១-លោក **ថន ម៉ិនថា** | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត | សមាជិក |
| ១២-លោក **ទ្រី វ៉ាន់ឌី** | ប្រធានរតនាគារខេត្ត | សមាជិក |
| ១៣-លោក លោកស្រី **អភិបាល** | នៃគណៈអភិបាលក្រុង ស្រុក | សមាជិក |
| ១៤-លោក **ពេជ្រ សុជាត** | ប្រធានការិយាល័យ នៃមន្ទីរមុខងារសាធារណៈ | ជនបង្គោល |
| ១៥-លោក **ស៊ឹម ពុទ្ធី** | ប្រធានការិយាល័យ នៃមន្ទីរមុខងារសាធារណៈ | ជនបង្គោល |

**ប្រការ២.-**

ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈ នៅរដ្ឋបាលខេត្តកំពង់ស្ពឺ មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

-ទទួលខុសត្រូវចំពោះមុខប្រធាន ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង និងដឹកនាំគ្រប់ការងារពាក់ព័ន្ធទៅនឹងកម្មវិធីយុទ្ធសាស្ត្រ និងសកម្មភាពកែទម្រង់រដ្ឋបាលសាធារណៈរបស់ខេត្ត

-សម្របសម្រួល និងជំរុញការអនុម័តគោលនយោបាយយុទ្ធសាស្ត្រ និងសកម្មភាពការងារកែទម្រង់រដ្ឋបាលសាធារណៈ

-រៀបចំផែនការសកម្មភាព កែទម្រង់រដ្ឋបាលសាធារណៈ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន

-តាមដានត្រួតពិនិត្យ និងវាយតម្លៃ ព្រមទាំងធ្វើរបាយការណ៍ ស្តីពីវឌ្ឍនភាពនៃការអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ ជូនប្រធានស្ថាប័នសាមីជាប្រចាំ

-រាយការណ៍អំពីវឌ្ឍនភាពឱ្យបានទៀងទាត់រាល់ត្រីមាសមកលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

-ផ្តល់កិច្ចសហការ និងសម្របសម្រួលជាមួយលេខាធិការដ្ឋាន នៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈតាមរយៈមន្ត្រីបង្គោលក្នុងការស្វែងរក និងប្រមូលព័ត៌មាន ការរៀបចំផែនការសកម្មភាពការតាមដានត្រួតពិនិត្យ និងវាយតម្លៃ ការរៀបចំរបាយការណ៍ និងបញ្ជូនរបាយការណ៍សង្ខេបនៃសូចនាករ ដែលទាក់ទងទៅនឹងវឌ្ឍនភាពនៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈរបស់រដ្ឋបាលខេត្តមកលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ឬនាយកដ្ឋានជំនាញ នៃក្រសួងមុខងារសាធារណៈ ជាពិសេសមន្ត្រីបង្គោលត្រូវចូលរួមវគ្គបណ្តុះបណ្តាលស្តីពីប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃសម្រាប់ការអនុវត្តកម្មវិធីជាតិ កំណែទម្រង់រដ្ឋបាលសាធារណៈ។

**ប្រការ៣.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយទៅនឹងដីកានេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤.-**

នាយករដ្ឋបាលសាលាខេត្ត អភិបាល នៃគណៈអភិបាលក្រុង ស្រុក នាយកទីចាត់ការ និងប្រធានអង្គភាពចំណុះរដ្ឋបាលខេត្ត ប្រធានមន្ទីរ អង្គភាពពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ខាងលើ ត្រូវអនុវត្តដីកានេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ៕

កំពង់ស្ពឺ ថ្ងៃទី....០៤.... ខែតុលា ឆ្នាំ២០១៦

**អភិបាលខេត្ត**

**ទ៊ុំ សំណាង**

**កន្លែងទទួល៖**

- ក្រសួងមហាផ្ទៃ
- ក្រសួងមុខងារសាធារណៈ (ដើម្បីគោរពជូនជ្រាប)
- គ្រប់សាលាក្រុង ស្រុក
- ដូចប្រការ៤
- ឯកសារ-កាលប្បវត្តិ